# ការបង្កើតយុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស

១. ធនាគារអភិវឌ្ឍន៍អាស៊ី បានរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រដំណើរការធ្វើផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាចាប់តាំងពី ADB បានចាប់ផ្តើមប្រតិបត្តិការឡើងវិញក្នុងឆ្នាំ ១៩៩៣។ ADB បានផ្តល់ជំនួយបច្ចេកទេសសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចទីពីរ (SEDP II) ដែលបានបង្កើតមូលដ្ឋានសម្រាប់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS)។ ជំនួយបច្ចេកទេសរបស់ ADB ចំពោះឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិដែលជា "ក្រុមផ្តល់ប្រឹក្សាជូននាយករដ្ឋមន្ត្រី" ក៏បានជាជំនួយផងដែរដល់ការរៀបចំយុទ្ធសាស្ត្រចតុកោណ សម្រាប់កំណើនការងារសមធម៌ និងភាពស័ក្តិសិទ្ធិ។

២. NPRS ត្រូវបានរៀបចំឡើងតាមរយៈដំណើរការចូលរួមមួយដែលរួមមានភាគីពាក់ព័ន្ធសំខាន់ៗ និងដែលត្រូវបានធ្វើឡើងដោយមានកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយដៃគូរអភិវឌ្ឍន៍របស់កម្ពុជា រួមទាំង ADB ផងដែរ។ ការរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស (CSP) នេះ អោយកិច្ចសហការប្រកបដោយជោគជ័យដែលសំរេចបានក្នុងការរៀបចំ NPRS អោយកាន់តែប្រសើរឡើង ការរៀបចំ CSP ត្រូវបានធ្វើឡើងក្នុងរយៈពេលដ៏វែងមួយ ចាប់តាំងពីត្រីមាសទីបីនៃឆ្នាំ ២០០២ រហូតដល់ចុងឆ្នាំ ២០០៤។ ដំណើរការរៀបចំ CSP នេះ គឺជាកិច្ចប្រឹងប្រែងទីមួយនៃកិច្ចប្រឹងប្រែងជាអន្តរជាតិទាំងឡាយ ដើម្បីរៀបចំឯកសារយុទ្ធសាស្ត្រមួយរួមគ្នាដោយដៃគូអភិវឌ្ឍន៍ ដោយមាន ADB សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) និង ធនាគារពិភពលោក។ ស្ថាប័នទាំងបីនេះ បានរៀបចំយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ប្រទេសកម្ពុជា ក្នុងពេលតែមួយ។

## ក. ការសម្របសម្រួលអ្នកផ្តល់ជំនួយដែលមិនដែលមានកាលពីពេលមុន

៣. ចាប់តាំងពីឆ្នាំ ២០០៣ មក ការជួបប្រជុំក្នុងចំណោមមន្ត្រីរៀបចំកម្មវិធីនៃស្ថាប័នទាំងបី ត្រូវបានរៀបចំឡើងក្នុងឆ្នាំ ២០០៣ នៅទីក្រុងភ្នំពេញ ម៉ានីល និងបាងកក ដើម្បីផ្លាស់ប្តូរព័ត៌មានគ្នា និងដើម្បីឈានដល់ការឯកភាពគ្នាលើចក្ខុវិស័យក៏ដូចជាជម្រើសទាំងឡាយ អំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នរៀងៗខ្លួនលើទិន្នផល និងលទ្ធផល។ ការប្រជុំរួមគ្នារបស់ភាគីទាំងបី គឺជាជំហានដ៏សំខាន់ឆ្ពោះទៅកាន់ការយល់ដឹងរួមគ្នាកម្រិតខ្ពស់អំពីក្របខ័ណ្ឌប្រតិបត្តិការក៏ដូចជាស្ថានភាពជាក់ស្តែងនៃដៃគូរទាំងឡាយ និងបាននាំអោយមានសេចក្តីថ្លែងការណ៍មួយស្តីពីគោលការណ៍នៃភាពជាដៃគូរ (សូមមើលប្រអប់ ក២)។

៤. នៅប្រទេសកម្ពុជា គេឃើញមានការអំពាវនាវជាទូទៅមួយដើម្បីឱ្យមានការសម្របសម្រួលដៃគូអភិវឌ្ឍន៍ទាំងឡាយ សំដៅបង្កើនការសំរបសំរួលការងារ។ ដៃគូអភិវឌ្ឍន៍ទាំងបី បានឯកភាពគ្នាលើការកសាងយុទ្ធសាស្ត្រនៃស្ថាប័ននីមួយៗ សម្រាប់ការផ្តល់ជំនួយក្នុងលក្ខណៈសម្របសម្រួលគ្នាជូនដល់កម្ពុជា។ ក្នុងអំឡុងពេលពីឆ្នាំ ២០០៥ ដល់ ២០០៩ សំដៅគាំទ្រការអនុវត្តន៍ប្រកបដោយជោគជ័យនូវកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ដូចមានបង្ហាញនៅក្នុង SEDP II NPRS និង យុទ្ធសាស្ត្រចតុកោណ។ ក្នុងការរៀបចំយុទ្ធសាស្ត្រនេះ លទ្ធផលដែលរំពឹងទុក ត្រូវបានរៀបចំជាពាក្យពេចន៍ឱ្យបានសមស្របដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ។ ស្ថាប័នទាំងបីបានឯកភាពគ្នាលើស្មារតីទទួលខុសត្រូវរួមគ្នាលើលទ្ធផលដែលត្រូវសំរេចបាន។ បណ្តាលទ្ធផលដ៏ទូលាយដែលត្រូវបានរំពឹងទុក មានដូចខាងក្រោមនេះ: (១) កែលំអរជីវភាពនៅជនបទ (២) ពង្រីកកាលានុវត្តភាពការងារ (៣) កែលំអរសមត្ថភាព (៤) ពង្រឹងស្ថាប័ននិងកែលំអរអភិបាលកិច្ច (៥) លើកស្ទួយសមភាពយេនដ័រ និង (៥) កាត់បន្ថយភាពងាយរងគ្រោះនិងពង្រឹងការចូលរួមសង្គម។ ស្ថាប័នទាំងបី ក៏បានឯកភាពគ្នាផងដែរលើក្របខ័ណ្ឌនៃការទទួលខុសត្រូវទូទៅក្នុងតួនាទីនាំមុខនិងការសំរេចបានលទ្ធផល។

៥. ក្រោយការជួបប្រជុំក្រៅផ្លូវការនិងការជួបប្រជុំថ្នាក់គ្រប់គ្រងមួយចំនួន សិក្ខាសាលារួមចំនួនពីរ ត្រូវបានប្រារព្ធធ្វើ។ សិក្ខាសាលាទីមួយ បានប្រព្រឹត្តទៅនៅបាងកកក្នុងខែ កញ្ញា ឆ្នាំ ២០០៣ និងបានពិភាក្សាអំពីវិធីដែលស្ថាប័នទាំងបីនឹងសហការគ្នា (រួមទាំងកិច្ចអភិវឌ្ឍន៍គោលការណ៍នៃភាពជាដៃគូរ)។ សិក្ខាសាលាទីពីរ នៅភ្នំពេញក្នុងខែ តុលា ឆ្នាំ ២០០៣ បានពិភាក្សាលទ្ធផលនៃយុទ្ធសាស្ត្រទាំងនេះ និងជំហានទាំងឡាយដែលចាំបាច់ដើម្បីសម្រេចបានលទ្ធផលទាំងនេះ។ កិច្ចប្រជុំទាំងនេះ បានគូសបង្ហាញការលំបាកក្នុងការរៀបចំកម្មវិធីការងាររួមគ្នាមួយ និង បាននាំឱ្យមានការបែងចែកការងារ និងកម្មវិធីមួយសម្រាប់ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ។

### ប្រអប់ ក២: គោលការណ៍ដឹកនាំលើភាពជាដៃគូរ

**ក: គោលការណ៍សហការការងារជាមួយរាជរដ្ឋាភិបាល**

- កសាងនិងរក្សាការយល់ដឹងរបស់យើងអំពីបរិបទអភិវឌ្ឍន៍នៃប្រទេសកម្ពុជា និងផ្អែកប្រតិបត្តិការរបស់យើងលើ ចំណេះដឹងនេះ។
- អភិវឌ្ឍការយល់ដឹងស៊ីជម្រៅអំពីតំរូវការនៃស្ថាប័ននៅក្នុងវិស័យនិមួយៗដែលយើងចូលរួម ដើម្បីលើកគំរោងការគាំទ្ររបស់យើងដោយផ្អែកលើចំណេះដឹងនេះ។
- កសាងសមត្ថភាពនៅក្នុងរាជរដ្ឋាភិបាល ដើម្បីដឹកនាំនិងអនុវត្តរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន

- យកចិត្តទុកដាក់លើរបៀបវារៈអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលផ្ទាល់ និងផ្អែកការពិភាក្សារបស់យើងដោយផ្អែកលើ របៀបវារៈទាំងនេះ។
- សហការជាមួយរាជរដ្ឋាភិបាលដើម្បីកំណត់អាទិភាពជម្រើសទាំងឡាយ និងតម្រង់យុទ្ធសាស្ត្ររបស់យើងដើម្បីគាំទ្រគំរោងអាទិភាពទាំងនេះ។
- រាជរដ្ឋាភិបាល ត្រូវបង្ហាញការប្តេជ្ញាចិត្ត និងភាពជាម្ចាស់មុនពេលសំរេចផ្តល់ការគាំទ្រចំពោះបទអន្តរាគមន៍ទាំងឡាយ។
- ការរំពឹងទុកនៃលទ្ធផលដែលអាចទទួលបានត្រូវមានលក្ខណសមស្រប មានចិត្តអំណត់ និងប្រកាន់យកទស្សនៈវិស័យវែងឆ្ងាយ។

**ខ: គោលការណ៍សម្រាប់វិធីដែលយើងនឹងធ្វើការងាររួមគ្នា**

- វិនិយោគពេលវេលានិងកិច្ចប្រឹងប្រែងលើការយល់ដឹងអំពីបណ្តាកាតព្វកិច្ចខុសៗគ្នារបស់យើង
- ទទួលស្គាល់ចំណុចខ្លាំងរបស់ស្ថាប័នរៀងៗខ្លួន និង ផ្អែកលើចំណុចខ្លាំងទាំងនេះ
- ធ្វើការក្នុងភាពជាដៃគូរ ដោយដោះស្រាយចំណុចមិនឯកភាពគ្នា និង រក្សាទំនុកចិត្ត
- កសាងនិងរក្សាទំនុកចិត្តគ្រប់គ្រាន់ដើម្បីតំណាងឱ្យផលប្រយោជន៍របស់គ្នាទៅវិញទៅមកចំពោះដៃគូរដទៃទៀត
- ចែករំលែកព័ត៌មានគ្នាក្នុងស្មារតីនៃតម្លាភាព
- បញ្ជូននិរក្សាសាររួមគ្នាជូនដល់រាជរដ្ឋាភិបាល
- ធ្វើអោយមានសង្គតភាពរវាងការិយាល័យប្រចាំប្រទេស និង ទីស្នាក់ការកណ្តាលនៃស្ថាប័ននីមួយៗ
- សម្របសម្រួលនិងធ្វើសុខុដុមនីយកម្មបណ្តាសកម្មភាពរបស់យើងនៅក្នុងវិស័យដែលយើងគាំទ្រ

៦. ផ្អែកលើកត្តាខាងលើនេះ ស្ថាប័ននីមួយៗបន្តជួបប្រជុំគ្នាដើម្បីអភិវឌ្ឍអភិក្រមរួមគ្នាមួយចំពោះការរៀបចំយុទ្ធសាស្ត្រប្រចាំប្រទេស។ ប្រការនេះ បាននាំឱ្យមានការវាយតម្លៃរួមគ្នាមួយលើនិន្នាការនិងបញ្ហាអភិវឌ្ឍន៍បច្ចុប្បន្ន យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងហានិភ័យចំពោះការអនុវត្តន៍យុទ្ធសាស្ត្រនោះ (សូមមើលជំពូក ១-២ និង និងផ្អែកខ្លះនៃជំពូក ៦ នៃ CSP)។ ស្ថាប័នទាំងបី បានផ្លាស់ប្តូរគ្នានូវការវាយតម្លៃមានស្រាប់របស់ពួកគេដែលបានកាត់បន្ថយចំពោះការងារជាន់គ្នា។ គេបានឯកភាពគ្នាថា អត្ថបទនៃឯកសារយុទ្ធសាស្ត្ររបស់ស្ថាប័នទាំងបីនឹងមានលក្ខណៈដូចគ្នានៅក្នុងផ្នែកទាំងនេះ។ ដោយសារ ADB បានសំរេចលទ្ធផលជាច្រើនក្នុងការរៀបចំ CSP របស់ខ្លួន ADB ក៏បាននាំមុខគេក្នុងការរៀបចំសេចក្តីព្រាងជំពូកទាំងនេះ។ អត្ថបទរួមគ្នានេះ ត្រូវបានចែក

រំលែកគ្នានៅក្នុងស្ថាប័នទាំងបី ហើយបន្ទាប់មក មតិយោបល់ត្រូវបានដាក់បញ្ចូល។ ថ្មីៗនេះ ប្រព័ន្ធអង្គការសហប្រជាជាតិ (UN) ក៏បានចូលរួមក្នុងដំណើរការរៀបចំយុទ្ធសាស្ត្ររួមនេះផងដែរ ហើយប្រព័ន្ធអង្គការសហប្រជាជាតិ នឹងប្រើប្រាស់ការវាយតម្លៃរួមនេះ សម្រាប់ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិឆ្នាំ ២០០៦-២០១០ របស់ខ្លួន។

## ក. ការពិគ្រោះយោបល់ និង ការចូលរួមរបស់ភាគីពាក់ព័ន្ធ

៧. ទន្ទឹមគ្នានឹងដំណើរការផ្ទៃក្នុងនៅក្នុងចំណោមដៃគូរទាំងបីនេះ គេឃើញមានការពិគ្រោះយោបល់មួយចំនួនជាមួយភាគីពាក់ព័ន្ធដ៏ទៃទៀតផងដែរ។ ក្នុងខែ តុលា ឆ្នាំ ២០០៣ គេឃើញមានសិក្ខាសាលាមួយចំនួនជាមួយសង្គមស៊ីវិល និងវិស័យឯកជនដើម្បីពិភាក្សាបញ្ហាប្រឈមសំខាន់ៗដែលប្រទេសជួបប្រទះ។ ការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលបាន បង្ហាញនូវភាពចាំបាច់ខ្លាំងឱ្យមានទំនាក់ទំនង និងកិច្ចសហការកាន់តែច្រើនឡើងរវាងសង្គមស៊ីវិល និងអ្នកផ្តល់ជំនួយមានគណនេយ្យភាព និងសំដៅអោយអភិបាលកិច្ចកាន់តែប្រសើរឡើង។ ការពិគ្រោះយោបល់ជាមួយវិស័យឯកជន ក៏បានសង្កត់ធ្ងន់ផងដែរលើសារៈសំខាន់នៃការកែលំអអភិបាលកិច្ច និងភាពចាំបាច់ឱ្យវិស័យឯកជន និងអ្នកផ្តល់ជំនួយធ្វើការរួមគ្នា និងយល់ពីគ្នាទៅវិញទៅមកឱ្យបានកាន់តែប្រសើរឡើង។

៨. ADB ដៃគូអភិវឌ្ឍន៍ទាំងឡាយ បានជួបជាមួយស្ថាប័នរាជរដ្ឋាភិបាលនៅក្នុងកម្រិតផ្សេងៗគ្នា ដើម្បីពិភាក្សាលើការរៀបចំ CSP។ ការជួបប្រជុំទាំងនេះ រួមមានការជួបប្រជុំជាន់ខ្ពស់មួយជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិក្នុងខែ កុម្ភៈ ឆ្នាំ ២០០៤ ដើម្បីពិភាក្សាយុទ្ធសាស្ត្រទូទៅនេះ។ កិច្ចប្រជុំមួយត្រូវបានរៀបចំជាមួយក្រសួងតាមវិស័យទាំងឡាយក្នុងខែ មិនា ឆ្នាំ ២០០៤ ដើម្បីពិភាក្សាការកំណត់ពេលវេលា និងសមាសភាពនៃកម្មវិធីនេះ។ បញ្ហានានា ដែលលើកឡើងដោយអន្តរស្ថាប័ន ក៏ត្រូវបានពិភាក្សាផងដែរក្នុងកិច្ចប្រជុំនេះ។ រាជរដ្ឋាភិបាល បានគាំទ្រអភិក្រមទូទៅរបស់ ADB និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃវិស័យកសិកម្ម និងប្រព័ន្ធធារាសាស្ត្រនៅក្នុងការជម្រុញកំណើន និងកាត់បន្ថយភាពក្រីក្រ។ តំណាងរាជរដ្ឋាភិបាល បានឯកភាពថា ការពង្រឹងស្ថាប័ន និងអភិបាលកិច្ច មានសារៈសំខាន់ បំផុតចំពោះការធានាឱ្យបានថា កម្ពុជានឹងអាចរក្សាបាននូវកិច្ចអភិវឌ្ឍន៍ប្រកបដោយអត្ថន័យ និងចីរភាព។

៩. បន្ថែមលើការជួបជាមួយភាគីពាក់ព័ន្ធក្នុងស្រុក ADB ក៏បានជួបពិភាក្សាច្រើនជាមួយដៃគូរអភិវឌ្ឍន៍អំពី CSP នេះ។ គោលបំណងនៃកិច្ចប្រជុំទាំងនេះ គឺដើម្បីទទួលយោបល់ និងដើម្បីកែលំអការសម្របសម្រួលអ្នកផ្តល់ជំនួយ។ សិក្ខាសាលាជាមួយអ្នកផ្តល់ជំនួយមួយ ត្រូវបានធ្វើឡើងនៅភ្នំពេញក្នុងខែ តុលា ឆ្នាំ ២០០៣ ដើម្បីពិភាក្សា

គោលការណ៍នៃភាពជាដៃគូរ និងការកែលំអរសុខុដុមនីយកម្មអ្នកផ្តល់ជំនួយ ។ ADB និងធនាគារពិភពលោក ក៏បានរៀបចំសិក្ខាសាលារួមគ្នាមួយផងដែរនៅក្នុងខែ មករា ឆ្នាំ ២០០៤ នៅតូក្យូ ដើម្បីពិភាក្សាដំណើរការរៀបចំយុទ្ធសាស្ត្រប្រចាំប្រចាំប្រទេសនេះជាមួយអាជ្ញាធរជប៉ុន ។ អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនោះ បានសង្កត់ធ្ងន់លើសារៈសំខាន់ដែលសហគមន៍អ្នកផ្តល់ជំនួយត្រូវនិយាយភាសាតែមួយ និងដោយមានយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងយុទ្ធសាស្ត្រចតុកោណធ្វើជាត្រីវិស័យនៃជំនួយអភិវឌ្ឍន៍ទាំងអស់ ។ គេក៏ឃើញមានផងដែរ នូវការប្តេជ្ញាចិត្តច្រើនលើការកែលំអរទំនាក់ទំនងការងារក្នុងចំណោមអ្នកផ្តល់ជំនួយ និង ការសម្របសម្រួលគ្នានៅក្នុងវិស័យនិមួយៗ ។ អ្នកផ្តល់ជំនួយ ក៏បានសង្កត់ធ្ងន់ផងដែរ លើសារៈសំខាន់នៃការផ្តោតការគាំទ្របន្ថែមទៀតលើតំបន់ជនបទ និងសារៈសំខាន់នៃការពង្រឹងវិមជ្ឈការ ។

១០. មតិទាំងឡាយដែលបានមកពីកិច្ចប្រជុំទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុង CSP និងមានឥទ្ធិពលយ៉ាងខ្លាំងលើការរៀបចំកម្មវិធី ។ កម្មវិធីនេះសំរាប់គាំទ្រដោយ ADB នាពេលខាងមុខ ត្រូវបានចែករំលែកគ្នាជាមួយ DFID និងធនាគារពិភពលោក ។

១១. សិក្ខាសាលាមួយ តូវបានរៀបចំធ្វើរួមគ្នាដោយ ADB DFID UN និងធនាគារពិភពលោក ក្នុងខែតុលា និង វិច្ឆិកា ឆ្នាំ ២០០៤ ដើម្បីផ្តល់យោបល់ជូនរាជរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងអ្នកផ្តល់ជំនួយដទៃទៀត អំពីប្រការដែលថាតើយោបល់របស់ពួកគេដែលបានប្រមូលកន្លងមក ត្រូវបានរាប់បញ្ចូលយ៉ាងដូចម្តេច តើស្ថាប័នទាំងបួននឹងគាំទ្រយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលយ៉ាងដូចម្តេច និងតើស្ថាប័នទាំងបួននេះ នឹងអនុវត្ត និងត្រួតពិនិត្យយុទ្ធសាស្ត្ររបស់ខ្លួនយ៉ាងដូចម្តេច ។